# បទឧទ្ទេសនាម
## របស់
## អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## ក្នុងកិច្ចប្រជុំពេញអង្គរដ្ឋសភា
## ស្ដីពី
## សេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤

*វិមានរដ្ឋសភា, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២៣*

ខ្ញុំសូមសម្ដែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ ជូនចំពោះ ៖

- សម្ដេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា;
- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី ១ នៃរដ្ឋសភា;
- ឯកឧត្តម **វង សូត** អនុប្រធានទី ២ នៃរដ្ឋសភា;
- សម្ដេច, ឯកឧត្តម, លោកជំទាវ, សមាជិក, សមាជិកា នៃរដ្ឋសភា និង អង្គរដ្ឋសភា ដ៏ឧត្ដុង្គឧត្ដម!

តាងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំសូមសម្ដែងនូវកតញ្ញុតាធម៌ដ៏ជ្រាលជ្រៅគោរពជូនចំពោះ **សម្ដេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា, គណៈអចិន្ត្រៃយ៍នៃរដ្ឋសភា, គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និង សវនកម្ម, ព្រមទាំងគណៈកម្មការពាក់ព័ន្ធទាំងអស់នៃរដ្ឋសភា, និង អង្គរដ្ឋសភាទាំងមូល, ដែលបានចាត់ការយ៉ាងរួសរាន់ ក្នុងការពិនិត្យ និង អនុម័ត ដាក់ **សេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់**

**ការគ្រប់គ្រង ឆ្នាំ ២០២៤** ចូលក្នុងរបៀបវារៈនៃសម័យប្រជុំពេញអង្គរដ្ឋសភា នាថ្ងៃនេះ ។ អាស្រ័យដោយរាជរដ្ឋាភិបាលបានរៀបចំសេចក្តីថ្លែងហេតុពិស្តារមួយ គោរពជូន **សម្តេច-មហារដ្ឋសភាធិការធិបតី** និង **អង្គរដ្ឋសភា** រួចហើយ, ហើយ **ឯកឧត្តម ឈាង ខុន** ក្នុងនាមគណៈកម្មការទី ២ នៃរដ្ឋសភា ក៏បានរាយការណ៍បន្ថែម គោរពជូនអង្គរដ្ឋសភាជ្រាបអម្បាញ់មិញ អំពីមូលដ្ឋានគតិយុត្ត, ទិដ្ឋភាពរួម, និង រចនាសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់នេះ; ដូច្នេះ, នៅពេលនេះ, ខ្ញុំសូមអនុញ្ញាតធ្វើបទឧទ្ទេសនាមដោយសង្ខេប ដើម្បីបានចំណេញពេល ។ យ៉ាងណាក៏ដោយ, ដូចសព្វដង, ខ្ញុំគោរពសុំការអភ័យទោសជាមុន ក្នុងករណីដែលខ្ញុំអាចថ្លែងឡើងវិញ ក្នុងគោលបំណងគូសបញ្ជាក់ ឬ សង្កត់ធ្ងន់បន្ថែម ឬ សម្រួចបន្ថែម នូវចំណុចមួយចំនួន នៅក្នុងបទឧទ្ទេសនាមរបស់ខ្ញុំ ដែលអាចជាន់គ្នានឹងអ្វីដែល **ឯកឧត្តម ឈាង ខុន** បានរាយការណ៍ជូនអង្គរដ្ឋសភា មុននេះ ។

## I. អំពីមូលដ្ឋានគតិយុត្ត និង រចនាសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់

សេចក្តីព្រាងច្បាប់នេះ ត្រូវបានរៀបចំស្របតាមការកំណត់ ដោយបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធ, ជាពិសេស ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៣, ទាំងទម្រង់, ខ្លឹមសារ និង កាលវសាន្ត ។ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០២៤ ត្រូវបានគណៈរដ្ឋមន្ត្រីពិនិត្យ និង សម្រេចយល់ព្រម ក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០២៣ ។

## II. អំពីបរិការណ៍ផ្នែកម៉ាក្រូសេដ្ឋកិច្ច និង គោលបំណងគោលនយោបាយនៃការរៀបចំថវិកាឆ្នាំ ២០២៤

សម្រាប់រយៈពេល ៥ ឆ្នាំខាងមុខ នៃនីតិកាលទី ៧ នៃរដ្ឋសភា, កម្ពុជានឹងត្រូវធ្វើដំណើរឆ្ពោះទៅដំណាក់កាលប្រែប្រួលថ្មីមួយទៀត ពោលគឺ ការឆ្លងកាត់អន្តរកាលទៅសម្រេចឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ ។ ប្រការនេះទាមទារនូវការយកចិត្តទុកដាក់ខ្ពស់ ចំពោះការលើកកម្ពស់ភាពជាអ្នកដឹកនាំ និង សមត្ថភាពស្ថាប័នគ្រប់កម្រិត ដោយផ្សារភ្ជាប់នឹងការធានាបាន នូវ គោលនយោបាយសមស្រប និង សមត្ថភាពអនុវត្តជាក់ស្តែង, លទ្ធផលការងារ និង ការទទួលខុសត្រូវ ដើម្បីឆ្លើយតបនឹងអាទិភាពសំខាន់ៗនៅក្នុងដំណាក់កាលថ្មីនេះ រួមមានជាអាទិ៍ ៖ ការពង្រឹងអភិបាលកិច្ច; ការទ្រទ្រង់កំណើន និង ការធ្វើទំនើបកម្មសេដ្ឋកិច្ច; ការបង្កើតការងារ, ទាំងគុណភាព

និង បរិមាណ; ការលើកស្ទួយវិស័យឯកជន និង សហគ្រិនភាព; ការកសាងមូលធនមនុស្ស ដោយផ្ដោតជាពិសេស លើគុណភាពវិស័យអប់រំ, សេវាសុខាភិបាល និង សីលធម៌សង្គម; ការលើកស្ទួយសេវាគាំពារសង្គម និង សុខុមាលភាពប្រជាជន, ជាពិសេស សម្រាប់គ្រួសារក្រីក្រ, គ្រួសារងាយរងហានិភ័យ និង ក្រុមជនងាយរងគ្រោះ; ការពង្រឹងគុណភាពនគរូបនីយកម្ម, ជាពិសេស ការកាត់បន្ថយគម្លាតរវាងទីក្រុង និង ជនបទ ។ល។

មួយវិញទៀត, ស្ថានភាពភូមិសាស្ត្រនយោបាយពិភពលោក ដែលកំពុងតែវិវត្តនៅក្នុងក្របខណ្ឌពហុប៉ូលនោះ ក៏មានសភាពកាន់តែស្មុគស្មាញឡើង, ហើយសេដ្ឋកិច្ចសកល ក៏បន្តមានកំណើនទាប និង ហ៊ុមព័ទ្ធដោយភាពមិនប្រាកដប្រជាខ្ពស់ ដែលបណ្ដាលមកពីសង្គ្រាមពាណិជ្ជកម្ម; ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍ក្នុងការឆ្លើយតបទៅនឹងសម្ពាធអតិផរណា; ការថមថយនៃសេដ្ឋកិច្ចរបស់បណ្ដាប្រទេសអភិវឌ្ឍន៍ដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា, ពិសេស សេដ្ឋកិច្ចចិន និង អឺរ៉ុប; ការអូសបន្លាយនៃសង្គ្រាមរវាងរុស្ស៊ី-អ៊ុយក្រែន; ការផ្ទុះឡើង ក្នុងពេលថ្មីៗ នូវសង្គ្រាមរវាងអ៊ីស្រាអែល និង ក្រុមហាម៉ាស់; ក៏ដូចជា ភាពកាន់តែស្រួចស្រាល់ឡើងនៃបញ្ហាការប្រែប្រួលអាកាសធាតុ ជាដើម ។ ប្រការទាំងនេះ បាន និង កំពុងបង្កផលប៉ះទង្គិចមួយចំនួនមកលើសេដ្ឋកិច្ចកម្ពុជា, ជាពិសេស លើពាណិជ្ជកម្ម និង លំហូរនៃការវិនិយោគ ។ ពិតណាស់ថា កម្ពុជា, ដែលជាប្រទេសមានសេដ្ឋកិច្ចបើកចំហខ្លាំង ហើយទទួលបានការរីកចម្រើនដោយសារសកលភាវូបនីយកម្ម, អាចនឹងទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមានពីកត្តាខាងក្រៅ ។ ក៏ប៉ុន្តែ ជាមួយគ្នានេះ, កម្ពុជា ក៏អាចនឹងទទួលបាននូវឱកាសមួយចំនួនវិញដែរ ក្នុងលក្ខខណ្ឌដែលយើងចេះបត់បែន និង មានភាពបុរេសកម្ម អាចឆ្លើយតបបានទាន់ពេល និង ប្រកបដោយប្រសិទ្ធភាព ទៅនឹងការប្រែប្រួលនៃសភាពការណ៍ ក្នុងតំបន់ និង លើពិភពលោក ដោយឈរលើអភិក្រម **«ប្រែក្លាយវិបត្តិ ឱ្យទៅជាកាលានុវត្តភាព»** ។ ដូចនេះ, កម្ពុជាក៏ត្រូវត្រៀមខ្លួនឱ្យបានល្អ ក្នុងការក្ដាប់យកនូវឱកាស និង ត្រូវចេះប្រើ-ប្រាស់លក្ខខណ្ឌអំណោយផល និង សក្ដានុពលទាំងឡាយដែលខ្លួនមាន សម្រាប់លើក-កម្ពស់ប្រសិទ្ធភាព និង ភាពប្រកួតប្រជែងសេដ្ឋកិច្ច ក៏ដូចជាកែលម្អបរិស្ថាននៃការធ្វើធុរកិច្ច និង ការវិនិយោគ ដើម្បីជំរុញសកម្មភាពធុរកិច្ច និង ទាក់ទាញបន្ថែមនូវការវិនិយោគដែលកំពុងតែផ្លាស់ប្ដូរទីតាំងពីតំបន់ផ្សេង ឱ្យចូលមកកម្ពុជា ។ ជាងនេះទៀត, កម្ពុជាក៏ត្រូវប្រឹងប្រែងទាញយកផលប្រយោជន៍ឱ្យបានជាអតិបរមា ពីការរីកចម្រើន និង ការវិវត្តយ៉ាងលឿននៃបច្ចេកវិទ្យា និង ឌីជីថលូបនីយកម្ម នៅក្នុងបរិការណ៍នៃបដិវត្តឧស្សាហកម្ម

ទី ៤ និង ត្រូវលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចការពារ និង ការអភិរក្សបរិស្ថាន ព្រមទាំងត្រូវសម្របខ្លួនឱ្យបានប្រសើរ ទៅនឹងការប្រែប្រួលអាកាសធាតុផងដែរ ។

ក្នុងបរិបទនេះ, ថវិកាឆ្នាំ ២០២៤ ត្រូវបានគិតគូរ និង រៀបចំឡើង ដើម្បីទ្រទ្រង់ដល់ការថែរក្សានូវសមិទ្ធផលនានា ដែលសម្រេចបានមកដោយលំបាក ក៏ដូចជាការអនុវត្តអាទិភាពគោលនយោបាយសំខាន់ៗ និង វិធានការកែទម្រង់ជាក់ស្តែងនានា ដែលនឹងត្រូវអនុវត្ត ចាប់ពីដើមនីតិកាលទី ៧ នៃរដ្ឋសភា និង ក្នុងឆ្នាំ ២០២៤ ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ថ្មីរបស់កម្ពុជា, ទាំងក្នុងក្របខណ្ឌផ្ទៃក្នុងប្រទេស, ក្នុងក្របខណ្ឌតំបន់ និង ពិភពលោក, ជាពិសេស ដើម្បីសម្រេចឱ្យបានជាអតិបរមា នូវ **គោលដៅជាយុទ្ធសាស្ត្រ ទាំង ៥** ដូចមានចែងក្នុង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដើម្បីកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេច **ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០** ដែលជា **របៀបវារៈគោល-នយោបាយសង្គម-សេដ្ឋកិច្ច** នៃ **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា** ។ ទន្ទឹមនេះដែរ, ថវិកាឆ្នាំ ២០២៤ ក៏បានផ្តោតការយកចិត្តទុកដាក់លើ **អាទិភាពគន្លឹះ ចំនួន ៥** នៃ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**, ដោយក្នុងនោះ **«មនុស្ស»** ត្រូវបានបន្តកំណត់ជាអាទិភាពគន្លឹះទី ១, ហើយ **ផ្លូវ, ទឹក, ភ្លើង** និង **បច្ចេកវិទ្យា** ជាអាទិភាពគន្លឹះបន្តបន្ទាប់តាមលំដាប់ ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និង ទិសដៅនៃការអភិវឌ្ឍកម្ពុជា ក្នុងដំណាក់កាលថ្មីខាងមុខ រួមមាន ៖ (១)-ការអភិវឌ្ឍមូលធនមនុស្ស, (២)-ការធ្វើពិពិធកម្មសេដ្ឋកិច្ច និង ការបង្កើនភាព-ប្រកួតប្រជែង, (៣)-ការអភិវឌ្ឍវិស័យឯកជន និង ការងារ, (៤)-ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និង បរិយាប័ន្ន, និង (៥)-ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល ។ បន្ថែមលើនេះ, ថវិកាឆ្នាំ ២០២៤ ក៏ត្រូវបានរៀបចំឡើងក្នុងគោលដៅគាំទ្រដល់ការ-អនុវត្ត **កម្មវិធីគោលនយោបាយអាទិភាពទាំង ៦** របស់រាជរដ្ឋាភិបាល ចាប់ពីដើមនីតិកាលទី ៧ នេះ ព្រមទាំង **វិធានការគន្លឹះ ចំនួន ៥** សម្រាប់ដោះស្រាយអាទិភាពមួយចំនួនទៀត ដែលត្រូវបានដាក់ចេញដោយ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** ក្នុងកិច្ចប្រជុំពេញអង្គលើកដំបូងនៃគណៈរដ្ឋមន្ត្រី នីតិកាលទី ៧ នៃរដ្ឋសភា, កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០២៣ កន្លងទៅ ។

តាមការវាយតម្លៃកាលពីពាក់កណ្តាលឆ្នាំ ២០២៣ នេះ, សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ ២០២៣ ត្រូវបានប៉ាន់ស្មានថា នឹងមានកំណើន ក្នុងអត្រា ៥,៦% ។ ក៏ប៉ុន្តែ, បញ្ហាប្រឈម

និង ហានិភ័យនានា, ទាំងក្នុង និង ក្រៅប្រទេស, ដូចខ្ញុំបានគូសរំលេចខាងដើម, បាន និង កំពុងបង្កផលប៉ះពាល់ជាអវិជ្ជមានមួយចំនួន មកលើសេដ្ឋកិច្ចកម្ពុជា, ជាពិសេស លើការ-នាំចេញ, ហើយវិស័យទេសចរណ៍កម្ពុជា ក៏ងើបឡើងវិញយឺតជាងការរំពឹងទុកផងដែរ នៅក្នុងឆមាសទី ២ ឆ្នាំ ២០២៣ នេះ ។ ដោយឡែក, សម្រាប់ឆ្នាំ ២០២៤, សេដ្ឋកិច្ចកម្ពុជា ត្រូវបានព្យាករថា នឹងសម្រេចបានកំណើន ក្នុងរង្វង់ **៦,៦%** ហើយ ផសស សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថា នឹងកើនឡើងដល់ **២ ០៧១** ដុល្លារអាម៉េរិក ធៀបនឹង **១ ៩១៧** ដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២៣ ។ ទោះជាយ៉ាងនេះក្តី, ស្ថិតក្នុងស្ថានភាពមិនប្រាកដប្រជាមួយចំនួនបែបនេះ, កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០២៣ និង ឆ្នាំ ២០២៤ អាចជួបនឹងបញ្ហាប្រឈមច្រើនជាងការរំពឹងទុក ដែល, ជាយថាហេតុ, ប្រការនេះ អាចនឹងធ្វើឱ្យកំណើនសេដ្ឋកិច្ចជារួម មានការប្រែប្រួលខ្លះ ធៀបនឹងការវាយតម្លៃកាលពីខែមិថុនា កន្លងទៅ ។

ហេតុដូច្នេះ, ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៤ ត្រូវបានត្រៀមរៀបចំក្នុងលក្ខណៈបត់បែនខ្ពស់ ដើម្បីសម្របទៅតាមលទ្ធផលជាក់ស្តែងនៃការប្រែប្រួលដែលអាចកើតមានជាយថាហេតុ ដោយឈរលើទស្សនវិជ្ជារួម របស់រាជរដ្ឋាភិបាល ពោលគឺ **«សង្ឃឹមសម្រាប់ស្ថានភាពប្រសើរ, តែត្រៀមខ្លួនសម្រាប់ស្ថានភាពអាក្រក់»** (Hope for the Best, But Prepare for the Worst) ។ លើមូលដ្ឋាននេះ, កម្ពុជានឹងអាចតស៊ូ ដើម្បីរស់រានបាន (Survive) ខណៈដែលសភាពការណ៍វិវត្តទៅអាក្រក់, ហើយនឹងអាចសម្រេចបានលទ្ធផលកាន់តែប្រសើរ នៅពេលសភាពការណ៍វិវត្តទៅល្អ ។

ក្នុងក្របខណ្ឌនៃបរិការណ៍រួម និង លើមូលដ្ឋាននៃសេចក្តីត្រូវការ ដូចបានគូស-បញ្ជាក់ខាងលើនេះ, រាជរដ្ឋាភិបាលបានប្រកាន់យកនូវជំហាននៃការអនុវត្ត **«គោលជំហរពង្រឹងប្រសិទ្ធភាពថវិកា»** (Fiscal Consolidation Stance) ចាប់ពីឆ្នាំ ២០២៤ ទៅ តាមរយៈវិធានការពង្រឹងការប្រមូលចំណូលពីគ្រប់ប្រភពដែលមានស្រាប់, ការពង្រឹងភាព-ធន់នៃថវិកា សម្រាប់ឆ្លើយតបនឹងវិបត្តិនានា, និង ការពង្រឹងប្រសិទ្ធភាពចំណាយ, ទាំងក្នុងទិដ្ឋភាពវិភាជន៍ និង ទិដ្ឋភាពប្រតិបត្តិការ, ដោយតម្រង់ធនធានទៅលើការគាំទ្រកំណើនសេដ្ឋកិច្ច និង ការអនុវត្តរបៀបវារៈគោលនយោបាយអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, ពិសេស ផ្តោតលើអាទិភាពសំខាន់ៗ **ចំនួន ១៣ ចំណុច** ដូចខាងក្រោម ៖

១- ការបន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ;

២- ការបន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ;
៣- ការបន្តស្តារ និង ជំរុញកំណើនសេដ្ឋកិច្ច ឱ្យស្ទុះងើបឡើងវិញ;
៤- ការបន្តពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ, ទាំងគុណភាព, ប្រសិទ្ធភាព, និង សមិទ្ធកម្មរបស់មន្ត្រី និង ស្ថាប័ន, តាមរយៈការលើកទឹកចិត្តចំពោះមន្ត្រីដែលមានគុណវុឌ្ឍិ ទន្ទឹមគ្នានឹងការបន្តដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ;
៥- ការបន្តដំឡើងរបបសោធនជូននិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈដែលជាអតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន;
៦- ការបន្តអភិវឌ្ឍមូលធនមនុស្ស;
៧- ការបន្តអភិវឌ្ឍប្រព័ន្ធសុខាភិបាល តាមរយៈការលើកកម្ពស់គុណភាពសេវាសុខាភិបាល គួបផ្សំជាមួយនឹងប្រព័ន្ធគាំពារសង្គម;
៨- ការបន្តការពង្រឹងគុណភាព និង ប្រសិទ្ធភាពនៃការវិនិយោគសាធារណៈ ក៏ដូចជា ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ឌីជីថល, និង បៃតង;
៩- ការបន្តអភិវឌ្ឍ និង ការបង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្ម;
១០- ការបន្តពង្រឹងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព»;
១១- ការបន្តនិរន្តរភាពនៃកិច្ចប្រតិបត្តិការរបស់រដ្ឋ និង គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាល;
១២- ការបន្តពង្រឹងភាពប្រកួតប្រជែង និង ការជំរុញពិពិធកម្មសេដ្ឋកិច្ច; និង
១៣- ការគាំទ្រដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី ៥ និង ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី-ខេត្ត, ក្រុមប្រឹក្សាក្រុង-ស្រុក និង ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី ៤ ។

ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាព ទៅនឹងអាទិភាពសំខាន់ដូចបានជម្រាបជូនខាងលើ, ថវិកាឆ្នាំ ២០២៤ ត្រូវបានរៀបចំឡើង ដោយផ្អែកលើអភិក្រម និង គោល-ការណ៍ **ចំនួន ៨** ដូចខាងក្រោម៖

**ទី១-គោរពឱ្យបាននូវក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច;**

**ទី២-រក្សាតុល្យភាព និង ចីរភាពថវិកា;**

**ទី៣-ធានាចីរភាព និង សមិទ្ធកម្មនៃចំណូល;**

ទី៤-តម្កល់ «មនុស្ស» ជាអាទិភាពទី ១;

ទី៥-ធ្វើវិចារណកម្មលំដាប់អាទិភាព;

ទី៦-កែលម្អការរៀបចំកម្មវិធី/សកម្មភាព;

ទី៧-ផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត; និង

ទី៨-ផ្សារភ្ជាប់រវាងការប្រមូលចំណូល និង ការវិភាជថវិកា ។

## III. អំពីក្របខណ្ឌថវិកាឆ្នាំ ២០២៤

ក្របខណ្ឌថវិកាឆ្នាំ ២០២៤ ត្រូវបានកំណត់ដូចតទៅ៖

១-ចំណូលសរុបថវិការដ្ឋ ឬ ចំណូលសរុបថវិកាជាតិ ត្រូវបានគ្រោងចំនួនប្រមាណ **៣២,៥ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៨ ប៊ីលានដុល្លារអាម៉េរិក**, ត្រូវជា **២២,៧៤%** នៃ ផសស ។ ក្របខណ្ឌថវិកាឆ្នាំ ២០២៤ មានគោលដៅបង្កើនចំណូលចរន្តថវិការដ្ឋ ឱ្យបានស្មើនឹង **២១,៩០%** នៃ ផសស ដែល**មានកំណើនចំនួន ០,៣៧ ពិន្ទុភាគរយនៃ ផសស** ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៣ ។

២-ចំណាយសរុបថវិការដ្ឋ ឬ ចំណាយសរុបថវិកាជាតិ ត្រូវបានគ្រោងចំនួនប្រមាណ **៣៧,១ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៩,១ ប៊ីលានដុល្លារអាម៉េរិក**, ស្មើនឹង **២៥,៩៦%** នៃ ផសស; ក្នុងនោះ, ចំណាយចរន្តថវិការដ្ឋ ត្រូវបានគ្រោងចំនួន **២៥,៩ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៦,៤ ប៊ីលាន ដុល្លារអាម៉េរិក**, ត្រូវជា ១៨,១១% នៃ ផសស, **កើនឡើង ១២,៩%** ធៀបនឹងច្បាប់ឆ្នាំ ២០២៣ ។

៣-អំពីការកំណត់ពិតាននៃការខ្ចី

នៅក្នុងរបាយការណ៍ជូនដល់អង្គរដ្ឋសភាមុននេះ, ឯកឧត្តម **ឈាង វុន** បាន រាយការណ៍លម្អិតរួចហើយ អំពីការកំណត់ពិតាននៃការខ្ចី ។ ដូច្នេះ, ត្រង់ចំណុចនេះ, ខ្ញុំគ្រាន់តែសូមគូសបញ្ជាក់ថា សម្រាប់ឆ្នាំ ២០២៤, រាជរដ្ឋាភិបាលគ្រោងធ្វើការខ្ចី ក្នុង ប្រទេស តាមរយៈការបោះផ្សាយមូលបត្ររដ្ឋ ចំនួន **៤៤០ ប៊ីលានរៀល**, សមមូលនឹង ប្រមាណ **១០៨ លានដុល្លារអាម៉េរិក** និង បានកំណត់ទំហំនៃការខ្ចីប្រាក់ពីដៃគូអភិវឌ្ឍន៍ **ចំនួន ១ ៧០០ លាន អេសដេអ៊ែ** ផងដែរ, ស្មើនឹងពិតាននៃការខ្ចីក្នុងឆ្នាំ ២០២៣, ដើម្បី ឆ្លើយតបទៅនឹងទំហំនៃតម្រូវការវិនិយោគសាធារណៈ សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច ។

ខ្ញុំក៏សូមគូសបញ្ជាក់ម្តងទៀតដែរថា ការបោះផ្សាយលក់មូលបត្ររដ្ឋ និង ការខ្ចីពីក្រៅប្រទេស ក្នុងទំហំខាងលើនេះ នឹងមិនបង្កើតជាបន្ទុកបំណុលវណ្ណករដល់កម្ពុជាទេ ពោលគឺជាទិដ្ឋភាពបច្ចេកទេស, ស្ថានភាពបំណុលសាធារណៈកម្ពុជា នៅតែត្រូវបានវាយតម្លៃថាមានចីរភាព និង ហានិភ័យកម្រិតទាបដដែល ដោយរាល់សូចនាករបំណុលគន្លឹះ របស់កម្ពុជា សុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់ ។

### ៤-តុល្យភាពរួមនៃថវិកាឆ្នាំ ២០២៤

នៅក្នុងក្របខណ្ឌថវិការដ្ឋ ឬ ថវិកាជាតិ, ទាំងថវិកាថ្នាក់ជាតិ និង ថវិកាថ្នាក់ក្រោមជាតិ, រាជរដ្ឋាភិបាលអាចរក្សាអតិរេកថវិកាចរន្តឱ្យបានក្នុងកម្រិតប្រមាណ **៣,៧៩%** នៃ ផសស នៅឆ្នាំ ២០២៤ ដែលជាលទ្ធផល, ឱនភាពសរុបថវិកាជាតិ នឹងមានទំហំស្មើនឹង **-៣,២២%** នៃ ផសស ។ ដូចនេះ, រាជរដ្ឋាភិបាល **មានតម្រូវការហិរញ្ញប្បទាន** ទំហំ **៣,២២%** នៃ ផសស ដើម្បី **បំពេញឱនភាពថវិកាជាតិ** ព្រមទាំង**មានតម្រូវការហិរញ្ញប្បទាន** ទំហំ **១,៤៨%** នៃ ផសស ស្មើនឹង **២ ១១៥ ប៊ីលានរៀល** សម្រាប់**ការទូទាត់ប្រាក់ខ្ចី** ដើម្បីរំលស់បំណុលសាធារណៈក្នុងប្រទេស និង ក្រៅប្រទេសផងដែរ ស្របតាមវិធាន និង នីតិវិធីថ្មីនៃការទូទាត់ប្រាក់ខ្ចី ដែលត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣ ។ សរុបជារួម, សម្រាប់ថវិកាឆ្នាំ ២០២៤, រាជរដ្ឋាភិបាល **មានតម្រូវការហិរញ្ញប្បទាន** ក្នុងទំហំ **៤,៧០%** នៃ ផសស ដែលនឹងត្រូវបានគាំទ្រដោយ **ហិរញ្ញប្បទានក្នុងប្រទេស** តាមរយៈការបោះផ្សាយមូលបត្ររដ្ឋ ក្នុងទំហំ **៤៤០ ប៊ីលានរៀល,** សមមូលនឹងប្រមាណ **១០៨ លានដុល្លារអាម៉េរិក**, និង **ហិរញ្ញប្បទានក្រៅប្រទេស** ក្នុងទំហំ **៤,៣៩%** នៃ ផសស ក្នុងនោះមាន ៖ មូលនិធិទ្រទ្រង់ថវិកា ទំហំ **០,៤៩%** នៃ ផសស និង ថវិកាវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ទំហំ **៣,៩០%** នៃ ផសស ។

## IV. អំពីគម្រោងចំណូល-ចំណាយថវិកាថ្នាក់ជាតិ

### ទី១- អំពីគម្រោងចំណូលថវិកាថ្នាក់ជាតិ

ថវិកាឆ្នាំ ២០២៤ មានគោលដៅបង្កើនចំណូលថវិកាថ្នាក់ជាតិ ឱ្យមានទំហំស្មើនឹង **២៩,៩ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៧,៤ ប៊ីលានដុល្លារអាម៉េរិក**, ត្រូវជា **២០,៩១%** នៃ ផសស ។ ក្នុងក្របខណ្ឌនេះ, ខ្លឹមសារពិស្តារនៃសេចក្តីថ្លែងហេតុលើសេចក្តីព្រាងច្បាប់នេះ បានរៀបរាប់រួចហើយអំពីគោលដៅសម្រាប់ចំណូលចរន្ត, ទាំង

គោលដៅចំណូលសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធ, ព្រមទាំងចំណូលផ្សេងៗ ក្នុងប្រទេស និង ក្រៅប្រទេស ។ ដូច្នេះ, ដើម្បីបានចំណេញពេល, ខ្ញុំសូមមិនអធិប្បាយនូវចំណុចទាំងអស់នេះឡើងវិញទេ ។

## ទី២- អំពីគម្រោងចំណាយថវិកាថ្នាក់ជាតិ

### ក. ចំណាយចរន្តថវិកាថ្នាក់ជាតិ

#### ក.១- អំពីទិដ្ឋភាពរួមនៃចំណាយចរន្តថវិកាថ្នាក់ជាតិ

ដូចបានគូសបញ្ជាក់នៅក្នុងអត្ថបទពិស្តារនៃសេចក្តីថ្លែងហេតុ លើសេចក្តីព្រាង-ច្បាប់នេះ, ថវិកាថ្នាក់ជាតិឆ្នាំ ២០២៤ មានទិសដៅជាយុទ្ធសាស្ត្រ កំណត់ចំណាយចរន្តឱ្យស្ថិតក្នុងកម្រិតប្រមាណ **២៣,៨ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **៥,៩ ប៊ីលានដុល្លារអាមេរិក**, ត្រូវជា **១៦,៦៥%** នៃ ផសស, **មានកំណើន ១៤,២%** ធៀបនឹងច្បាប់ឆ្នាំ ២០២៣, ដែល ក្នុងនោះ៖

ក.១.១-ចំណាយលើបន្ទុកបុគ្គលិក ត្រូវបានគ្រោងប្រមាណ **១០,៣ ទ្រីលានរៀល**, មានសមាមាត្រស្មើនឹង **៤៣,១% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ**, ត្រូវជា **៧,១៧%** នៃ ផសស, **មានកំណើន ៧,៣%** ធៀបនឹងច្បាប់ឆ្នាំ ២០២៣ ។ ចំណាយបន្ទុកបុគ្គលិកត្រូវបានគ្រោងគិតគូរ ដោយផ្តោតអាទិភាពជាពិសេស លើការដំឡើងបៀវត្សជូនមន្ត្រីរាជការគ្រប់ប្រភេទ និង ការដំឡើងប្រាក់សោធន ជូនអតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន ។ តាមរយៈការបន្តអនុវត្តគោលនយោបាយដំឡើងបៀវត្សនេះ, មន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធ ទទួលបានការដំឡើងប្រាក់បៀវត្សជាមធ្យម **៦ ម៉ឺនរៀល ក្នុង ១ ខែ** ។ ដូចនេះ, ស្ថានភាពបៀវត្សអប្បបរមា របស់មន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធ នៅឆ្នាំ ២០២៤ នឹងប្រែប្រួលដូចខាងក្រោម ៖

- បៀវត្សអប្បរមាមន្ត្រីរាជការស៊ីវិល នឹងត្រូវបានដំឡើងពី **១ ៣០០ ០០០ រៀល** នៅឆ្នាំ ២០២៣ ដល់ប្រមាណ **១ ៣៥៦ ៩៥០ រៀល**;
- បៀវត្សអប្បរមាគ្រូបង្រៀន និង គ្រូពេទ្យ នឹងត្រូវបានដំឡើងពី **១ ៤០០ ០០០ រៀល** នៅឆ្នាំ ២០២៣ ដល់ប្រមាណ **១ ៤៥៦ ៩៥០ រៀល**;
- បៀវត្សអប្បរមានគរបាលជាតិ (ពលបាលត្រី) នឹងត្រូវបានដំឡើងពី **១ ៣៨៤ ៤៧៧ រៀល** (ដោយគិតបញ្ចូលទាំងរបបអង្គរ) នៅឆ្នាំ ២០២៣ ដល់ប្រមាណ **១ ៤៤៣ ៩២៧ រៀល** (ដោយគិតបញ្ចូលទាំងរបបអង្គរ);

➢ បៀវត្សអប្បបរមាយោធិន (ពលទោ) នឹងត្រូវបានដំឡើងពី **១ ២៥១ ០០០ រៀល** (ដោយមិនទាន់គិតបញ្ចូលរបបអង្គរ) នៅឆ្នាំ ២០២៣ ដល់ប្រមាណ **១ ៣០៦ ៩៥០ រៀល** (ដោយមិនទាន់គិតបញ្ចូលរបបអង្គរ), ហើយបើគិតបញ្ចូលទាំងរបបអង្គរ, ត្រូវជាប្រមាណ **១ ៣៦៥ ០២៧ រៀល** ។

ចំពោះ ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យា ក៏នឹងត្រូវបានដំឡើងពី **៧១ ម៉ឺនរៀល** នៅឆ្នាំ ២០២៣ ទៅដល់ **៧៧ ម៉ឺនរៀល** នៅឆ្នាំ ២០២៤ ផងដែរ ។

ទន្ទឹមនេះ, រាជរដ្ឋាភិបាលនឹងដំឡើងប្រាក់សោធន ព្រមទាំងនឹងធ្វើសមាហរណកម្មប្រាក់សោធនតាមប្រព័ន្ធបៀវត្សចាស់ ចូលទៅក្នុងប្រព័ន្ធបៀវត្សថ្មី ដើម្បីដោះស្រាយបញ្ហាគម្លាតរវាងអ្នកចូលនិវត្តចាស់ និង ថ្មី ឱ្យបានចប់នៅក្នុងឆ្នាំ ២០២៤ ។ តាមរយៈវិធានការនេះ, ប្រាក់សោធនអប្បបរមាប្រចាំខែរបស់អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន (អតីតយោធិន និង អតីតមន្ត្រីនគរបាលជាតិ) ត្រូវបានដំឡើងពី **៧៧ ម៉ឺនរៀល** នៅឆ្នាំ ២០២៣ ដល់ **៨២,៥ ម៉ឺនរៀល** នៅឆ្នាំ ២០២៤ ។

សូមជម្រាបជូនថា កាលបរិច្ឆេទសម្រាប់ការអនុវត្តការដំឡើងប្រាក់បៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់មុខងារ ជូនដល់មន្ត្រីរាជការ ព្រមទាំងការដំឡើង ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យា និង ការដំឡើងប្រាក់សោធនប្រចាំខែជូនអតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន ក៏ដូចជាប្រាក់ឧបត្ថម្ភផ្សេងៗ នឹងត្រូវកំណត់ ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល នាពេលខាងមុខ ។

ជាមួយគ្នានេះ, រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាចំនួន **៩៥ ប៊ីលានរៀល** សម្រាប់ការថែទាំសុខភាពមន្ត្រីរាជការស៊ីវិល, កងកម្លាំងប្រដាប់អាវុធ និង និវត្តជន ព្រមទាំងបានបន្តគ្រោងថវិកាចំនួន **៦ ប៊ីលានរៀល** សម្រាប់របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារជូនមន្ត្រីសាធារណៈ ផងដែរ ។

ក.១.២-ចំណាយក្រៅបន្ទុកបុគ្គលិក ត្រូវបានគ្រោងចំនួនប្រមាណ **១៣,៦ ទ្រីលានរៀល**, មានសមាមាត្រស្មើនឹង **៥៦,៩% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ**, ត្រូវជា ៩,៤៨% នៃ ផសស, មានកំណើន **២០,១%** ធៀបនឹងច្បាប់ ឆ្នាំ ២០២៣ ។ **ការគ្រោងកើនឡើងនេះ គឺដើម្បីបំពេញសេចក្តីត្រូវការចាំបាច់របស់ក្រសួង-ស្ថាប័ន ក្នុងការអនុវត្តការងារអាទិភាពរបស់ខ្លួន និង ការងារកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល, ជាពិសេស ផ្តោត**

**លើការគាំទ្រកម្មវិធីគោលនយោបាយអាទិភាព ចំនួន ៦ របស់រាជរដ្ឋាភិបាល ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា និង ការគាំទ្រការអនុវត្តវិធានការគន្លឹះ ចំនួន ៥ សម្រាប់ដោះស្រាយអាទិភាព ដែលត្រូវបានដាក់ចេញដ៏ខ្ពង់ខ្ពស់ ដោយ សម្តេចធិបតី នាយករដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គលើកដំបូងនៃគណៈរដ្ឋមន្ត្រី នីតិកាលទី ៧ នៃរដ្ឋសភា**, ដែលខ្ញុំនឹងជម្រាបជូនជាសង្ខេប អំពីទំហំថវិកាដែលត្រូវបានគ្រោង ទៅតាមអាទិភាព និង វិធានការនីមួយៗ នៅផ្នែកខាងក្រោម ។

## ខ- អំពីគម្រោងចំណាយមូលធនថវិកាថ្នាក់ជាតិ

**ចំណាយមូលធនថ្នាក់ជាតិ** ត្រូវបានគ្រោង**ប្រមាណ ១០,៧ ទ្រីលានរៀល**, សមមូលនឹងប្រមាណ **២,៦ ប៊ីលានដុល្លារអាម៉េរិក**, មានសមាមាត្រស្មើនឹង **៣០,១% នៃចំណាយសរុបនៃថវិកាថ្នាក់ជាតិ**, ត្រូវជា **៧,៤៨%** នៃ ផសស, ដែលក្នុងនោះ **គម្រោងវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ** ត្រូវបានគ្រោង ក្នុងទំហំប្រមាណ **៣,១៤%** នៃ ផសស ។ អាទិភាពនៃចំណាយវិនិយោគផ្ទាល់ ដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានផ្តោតលើ៖

១-ការបន្តកសាង និង ជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ដែលរួមបញ្ចូលនូវការជួសជុលឡើងវិញ នូវហេដ្ឋារចនាសម្ព័ន្ធដែលរងផលប៉ះពាល់ពីជំនន់ទឹកភ្លៀង ក៏ដូចជាការសាងសង់ និង ជួសជុលផ្លូវ, ស្ពាន, ប្រព័ន្ធចម្រោះទឹកកខ្វក់, ប្រព័ន្ធលូ, អូរ, ប្រឡាយរំដោះទឹកភ្លៀង និង ប្រព័ន្ធបង្ហូរទឹកកខ្វក់ ជាដើម;

២-ការបន្តស្តារ និង កសាងប្រព័ន្ធធារាសាស្ត្រ និង លើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ;

៣-ការជំរុញផលិតកម្មស្បៀង និង ការលើកកម្ពស់ផលិតភាពកសិកម្ម; និង

៤-ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យអប់រំ និង បណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ព្រមទាំងការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យសុខាភិបាល និង ការសាង-សង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ឆ្លើយតបទៅនឹងតម្រូវការចាំបាច់ របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាការអនុវត្តកម្មវិធីសាច់ប្រាក់ពលកម្ម (Cash for works) ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធតូចៗនៅជនបទ, ការអនុវត្តមូលនិធិអភិវឌ្ឍន៍ជំនាញ និង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង បៃតង ជាដើម ។

ឆ្លៀតក្នុងឱកាសនេះដែរ, ខ្ញុំសូមគូសរំលេចអំពីទំហំថវិកាដែលត្រូវបានរៀបចំ ដើម្បីគាំទ្រដល់ **កម្មវិធីគោលនយោបាយអាទិភាព ចំនួន ៦** និង **ការអនុវត្តវិធានការគន្លឹះ ចំនួន ៥** សម្រាប់ការដោះស្រាយអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា ដូចខាងក្រោម ៖

**កម្មវិធីគោលនយោបាយអាទិភាព ចំនួន ៦ រួមមាន ៖**

**១-ការពង្រីកសេវាថែទាំសុខភាព** ឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល ត្រូវបានផ្តល់ថវិកាសរុបចំនួន **៣៤០,៤ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **៨៣ លានដុល្លារអាមេរិក**;

**២-ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និង បច្ចេកទេស** ដល់យុវជនមកពីគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស ត្រូវបានផ្តល់ថវិកាសរុបចំនួន **១៤៦,៦ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **៣៦ លានដុល្លារអាមេរិក**;

**៣-ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គម** សម្រាប់គ្រួសារក្រីក្រ, ក្រុមជន-ងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យ នៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និង គ្រាមានគ្រោះអាសន្ន ត្រូវបានគ្រោងថវិកាចំនួន **៦៧៤,៥ ប៊ីលានរៀល,** សមមូលនឹងប្រមាណ **១៦៥ លានដុល្លារអាមេរិក**;

**៤-ការអនុវត្តយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ** ឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និង អាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ ។ សម្រាប់ការអនុវត្តយុទ្ធសាស្ត្រនេះ, ក្រសួង-ស្ថាប័នទទួលបន្ទុក មិនទាន់បានរៀបចំរួចរាល់នូវតម្រូវការថវិកាជាក់លាក់នៅឡើយ ។ យ៉ាងណាមិញ, ក្នុងករណីមានតម្រូវការថវិកាចាំបាច់សម្រាប់កម្មវិធីនេះ, រាជរដ្ឋាភិបាលអាចពិនិត្យយកចេញមួយចំណែកពីកញ្ចប់ថវិកា ក្នុងទំហំប្រមាណ **៤១០ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **១០០ លានដុល្លារអាមេរិក** ដែលត្រូវបានត្រៀមសម្រាប់គោលនយោបាយថ្មី;

**៥-យន្តការសម្របសម្រួល និង កម្មវិធីហិរញ្ញប្បទាន** សំដៅលើកស្ទួយផលិតកម្ម, រកទីផ្សារ និង រក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ ត្រូវបានគ្រោងថវិកា **ចំនួន ៤១០ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **១០០ លានដុល្លារអាមេរិក**; និង

**៦-ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់** ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស ដើម្បីជំរុញការលើកកម្ពស់ផលិតភាពកសិកម្ម និង ជួយដល់

គ្រួសារកសិករ ក្នុងការលើកស្ទួយផលិតផលកសិកម្មរបស់ខ្លួន និង ការរៀបចំឱ្យមានសហគមន៍កសិកម្មនៅតាមទីជនបទ ត្រូវបានគ្រោងថវិកាចំនួន ១៦,៩ **ប៊ីលានរៀល,** សមមូលនឹងប្រមាណ **៤ លានដុល្លារអាមេរិក** ។

**ការអនុវត្តវិធានការគន្លឹះ ចំនួន ៥ រួមមាន ៖**

១-**ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ** ដោយផ្តោតជាសំខាន់លើការពង្រឹងគុណភាព, ប្រសិទ្ធភាព, និង សមិទ្ធកម្មរបស់មន្ត្រី និង ស្ថាប័ន ត្រូវបានត្រៀមថវិកាចំនួន **៤៩២ ប៊ីលានរៀល,** សមមូលនឹងប្រមាណ **១២០ លានដុល្លារអាមេរិក**;

២-**ការលើកកម្ពស់គុណភាពអប់រំ** ដោយផ្តោតជាសំខាន់លើការពង្រឹងគុណភាពសាលារដ្ឋ, ចាប់ពីថ្នាក់មត្តេយ្យ ដល់មធ្យមសិក្សា, ត្រូវបានគ្រោងថវិកាចំនួន **៤១៩ ប៊ីលានរៀល,** សមមូលនឹងប្រមាណ **១០២ លានដុល្លារអាមេរិក**;

៣-**ការលើកកម្ពស់គុណភាពសេវាសុខាភិបាល** ដោយផ្តោតជាសំខាន់លើការពង្រឹងសមត្ថភាពផ្តល់សេវាសុខភាពបឋមនៅមូលដ្ឋាន ត្រូវបានគ្រោងថវិកាចំនួន **២៤១ ប៊ីលានរៀល,** សមមូលនឹងប្រមាណ **៥៩ លានដុល្លារអាមេរិក**;

៤-**ការពង្រឹងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព»** ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការកាត់បន្ថយ និង ឈានទៅដល់ការលុបបំបាត់ការជួញដូរ និង ប្រើប្រាស់គ្រឿងញៀនក្នុងសហគមន៍ ត្រូវបានគ្រោងថវិកាចំនួន **៣៨,១ ប៊ីលានរៀល,** សមមូលនឹងប្រមាណ **៩ លានដុល្លារអាមេរិក**; និង

៥-**ការបន្តពង្រឹង និង លើកកម្ពស់គុណភាព និង ប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌** ត្រូវបានគ្រោងថវិកាចំនួន ១០,៣ **ប៊ីលានរៀល,** សមមូលនឹងប្រមាណ **២,៥ លានដុល្លារអាមេរិក** ។

## V. អំពីគម្រោងចំណូល-ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

**គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត, ក្រុង-ស្រុក និង ឃុំ-សង្កាត់** មានទំហំឥណទានថវិកាចំនួនប្រមាណ **១,៧ ទ្រីលានរៀល** ដែលត្រូវបានគ្រោងឧបត្ថម្ភធនបំពេញតុល្យភាពដោយថវិកាថ្នាក់ជាតិ សម្រាប់បែងចែកជូនទៅថ្នាក់រដ្ឋបាលនីមួយៗ ។ ការឧបត្ថម្ភនេះ **មានកំណើន ១៧,៨%** ធៀបនឹងច្បាប់ឆ្នាំ ២០២៣, ត្រូវជា **១,២០%** នៃ ផសស ។

សូមគូសបញ្ជាក់ដែរថា រដ្ឋបាលឃុំ-សង្កាត់នីមួយៗ ទទួលបានថវិកាសរុបជាមធ្យមប្រមាណ **៧៦៣ លានរៀល** ឬ សមមូលនឹង **១៨៨ ៣០០ ដុល្លារអាម៉េរិក;** ក្នុងនោះចំពោះថវិកាផ្នែកអភិវឌ្ឍន៍មូលដ្ឋាន, ឃុំ-សង្កាត់នីមួយៗ ទទួលបានជាមធ្យមប្រមាណ **៤១០ លានរៀល** ឬ សមមូលនឹង **១០១ ០០០ ដុល្លារអាម៉េរិក** ក្នុង ១ ឆ្នាំ, កើនឡើង **១៤,៥%** ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣ ។

ដូចគ្នានឹងថ្នាក់ជាតិដែរ, ក្នុងឆ្នាំ ២០២៤, ប្រាក់បំណាច់របស់ប្រធានក្រុមប្រឹក្សារាជធានី-ខេត្ត, ប្រធានក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ, ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ នឹងទទួលបានការដំឡើង **ចំនួន ៨ ម៉ឺនរៀល**, ចំពោះសមាជិកនៃក្រុមប្រឹក្សានីមួយៗ នឹងទទួលបានការដំឡើង **ចំនួន ៥ ម៉ឺនរៀល** ។ ទន្ទឹមនេះ, ថ្នាក់ដឹកនាំភូមិ រួមមាន ៖ ប្រធានភូមិ, អនុប្រធានភូមិ និង សមាជិកភូមិ ក៏នឹងទទួលបានការដំឡើង **ចំនួន ៤ ម៉ឺនរៀល** ផងដែរ ។ ដូចនេះ, ស្ថានភាពប្រាក់បំណាច់របស់ក្រុមប្រឹក្សារាជធានី-ខេត្ត, ក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ, ក្រុមប្រឹក្សា-ឃុំ-សង្កាត់ និង ថ្នាក់ដឹកនាំភូមិ ក្នុងឆ្នាំ ២០២៤ នឹងប្រែប្រួល ដូចខាងក្រោម ៖

-**សម្រាប់ប្រធានក្រុមប្រឹក្សារាជធានី-ខេត្ត** នឹងកើនពី ១ ៥៧០ ០០០ រៀល ក្នុងឆ្នាំ ២០២៣ ដល់ **១ ៦៥០ ០០០ រៀល** ក្នុងឆ្នាំ ២០២៤;

-**សម្រាប់សមាជិកក្រុមប្រឹក្សារាជធានី-ខេត្ត** នឹងកើនពី ១ ១៩៥ ០០០ រៀល ក្នុងឆ្នាំ ២០២៣ ដល់ **១ ២៤៥ ០០០ រៀល** ក្នុងឆ្នាំ ២០២៤;

-**សម្រាប់ប្រធានក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ** នឹងកើនពី ១ ២៨៥ ០០០ រៀល ក្នុងឆ្នាំ ២០២៣ ដល់ **១ ៣៦៥ ០០០ រៀល** ក្នុងឆ្នាំ ២០២៤;

-**សម្រាប់សមាជិកក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ** នឹងកើនពី ៩៧០ ០០០ រៀល ក្នុងឆ្នាំ ២០២៣ ដល់ **១ ០២០ ០០០ រៀល** ក្នុងឆ្នាំ ២០២៤;

-**សម្រាប់ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់** នឹងកើនពី ១ ២៤០ ០០០ រៀល ក្នុងឆ្នាំ ២០២៣ ដល់ **១ ៣២០ ០០០ រៀល** ក្នុងឆ្នាំ ២០២៤;

-**សម្រាប់ជំទប់ទី ១, ជំទប់ទី ២, ចៅសង្កាត់រងទី ១, ចៅសង្កាត់រងទី ២** នឹងកើនពី ៩៣០ ០០០ រៀល ក្នុងឆ្នាំ ២០២៣ ដល់ **៩៨០ ០០០ រៀល** ក្នុងឆ្នាំ ២០២៤;

-**សម្រាប់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់** នឹងកើនពី ៨២០ ០០០ រៀល ក្នុងឆ្នាំ ២០២៣ ដល់ **៨៧០ ០០០ រៀល** ក្នុងឆ្នាំ ២០២៤;

-**សម្រាប់មេភូមិ** នឹងកើនពី ៥១០ ០០០ រៀល ក្នុងឆ្នាំ ២០២៣ ដល់ **៥៥០ ០០០ រៀល** ក្នុងឆ្នាំ ២០២៤;

-**សម្រាប់អនុប្រធានភូមិ** នឹងកើនពី ៣៩០ ០០០ រៀល ក្នុងឆ្នាំ ២០២៣ ដល់ **៤៣០ ០០០ រៀល** ក្នុងឆ្នាំ ២០២៤; និង

-**សម្រាប់សមាជិកភូមិ** នឹងកើនពី ៣៦០ ០០០ រៀល ក្នុងឆ្នាំ ២០២៣ ដល់ **៤០០ ០០០ រៀល** ក្នុងឆ្នាំ ២០២៤ ។

លើសពីនេះទៀត, គួរកត់សម្គាល់ថា ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏នៅត្រូវគិតបញ្ចូលនូវកញ្ចប់ថវិការបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី-ខេត្ត ដែលជាការប្រគល់មុខងារមានភ្ជាប់លក្ខខណ្ឌ ក្នុងវិស័យសុខាភិបាល ទៅឱ្យរដ្ឋបាលរាជធានី-ខេត្ត និង កញ្ចប់ថវិកានៃការប្រគល់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំ ចំនួន ៣ ផ្សេងទៀត ដែលរួមមាន ៖ មុខងារគ្រប់គ្រងការអប់រំកុមារតូច, មុខងារគ្រប់គ្រងការអប់រំបឋមសិក្សា និង មុខងារគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ ទៅឱ្យគ្រប់រដ្ឋបាលក្រុង-ស្រុក-ខណ្ឌទាំងអស់ ទូទាំងប្រទេស ។ ដូចនេះ, បន្ទាប់ពីច្បាប់ហិរញ្ញវត្ថុត្រូវបានអនុម័ត, ក្នុងក្របខណ្ឌនៃការអនុវត្តថវិកា, កញ្ចប់ថវិកាចំណាយចរន្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងមានទំហំសរុបស្មើនឹង **៦ ៤៣៤ ប៊ីលានរៀល** មានសមាមាត្រស្មើនឹង **២៤,៩%** នៃចំណាយចរន្តសរុបនៃថវិការដ្ឋ ត្រូវជា **៤,៥០%** នៃ ផសស, កើនឡើង **៤១,៦%** ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣ ។

## VI. បញ្ហាប្រឈម និង វិធានការក្នុងការអនុវត្តច្បាប់ថវិកាឆ្នាំ ២០២៤

ការអនុវត្តក្របខណ្ឌថវិកាខាងលើ តម្រូវឱ្យរាជរដ្ឋាភិបាលខិតខំជម្នះនូវការលំបាក និង បញ្ហាប្រឈមមួយចំនួន, ទាំងផ្នែកចំណូល និង ផ្នែកចំណាយ, តាមរយៈការដាក់ចេញនូវវិធានការមុតស្រួចទាំងឡាយ, ទាំងផ្នែកចំណូល និង ទាំងផ្នែកចំណាយ, ដូចបានរៀបរាប់លម្អិតនៅក្នុងអត្ថបទសេចក្តីថ្លែងហេតុ; ដូច្នេះ, ខ្ញុំសូមអនុញ្ញាតមិនអធិប្បាយឡើងវិញទេ ។

## VII. សេចក្តីសន្និដ្ឋាន

សរុបជារួម, ថវិកាឆ្នាំ ២០២៤ អាចត្រូវបានសន្និដ្ឋានថា ជាឧបករណ៍ដ៏មានប្រសិទ្ធភាព ដែលនឹងជួយឱ្យរាជរដ្ឋាភិបាល អាចឆ្លើយតបទៅនឹងបញ្ហាប្រឈម និង ហានិភ័យផងទាំងពួង, ទាំងក្នុង និង ក្រៅប្រទេស ។ ថវិកានេះ ត្រូវបានរៀបចំឡើងដោយប្រកាន់យកនូវជំហាននៃការអនុវត្ត «**គោលជំហរពង្រឹងប្រសិទ្ធភាពថវិកា**» (Fiscal

Consolidation Stance) ដោយផ្ដោតការយកចិត្តទុកដាក់ជាពិសេស លើមនុស្ស និង លើសមត្ថភាពស្ថាប័ន ពោលគឺ ការកែទម្រង់រដ្ឋបាលសាធារណៈ និង ការកែទម្រង់រចនាសម្ព័ន្ធ ដែលមានអភិបាលកិច្ចជាស្នូល, និង លើប្រសិទ្ធភាព និង ភាពធន់នៃសេដ្ឋកិច្ច និង សង្គម ហើយអាចប្រសិទ្ធនាមបានថា ជា «**ថវិកាយុទ្ធសាស្ត្រនៃការរក្សាសមិទ្ធផលដែលសម្រេចបានដោយលំបាក និង ការបន្តបុកគ្រឹះថ្មីៗ ក្នុងការបោះជំហានឆ្ពោះទៅសម្រេចគោលដៅសំខាន់ៗ** នៃ **កម្មវិធីនយោបាយ** និង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា ដើម្បីបន្តរក្សាសុខសន្តិភាព, ស្ថិរភាព និង ទ្រទ្រង់ដំណើរវិវឌ្ឍន៍តទៅមុខឥតឈប់ឈរ របស់កម្ពុជា លើវិថីនៃការអភិវឌ្ឍ ប្រកបដោយគុណភាព និង ចីរភាព ឆ្ពោះទៅចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០» ។

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ, សូម **សម្ដេចមហារដ្ឋសភាធិការធិបតី** និង **អង្គរដ្ឋសភាទាំងមូល** មេត្តាពិនិត្យ និង ផ្ដល់ការអនុម័តលើ **សេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤** ដោយអនុគ្រោះ ។

*សូមអរគុណ!*